# ចរណៈ ១៥ យ៉ាង

ក្នុងអត្ថបទនេះនឹងលើកយកចរណៈ១៥របស់ព្រះសម្មាសម្ពុទ្ធមក និយាយជាបន្តទៅទៀត គ្រាន់បានជាឈ្នួននៃសតិបញ្ញាក្នុងការសិក្សាវិះគិតតទៅ។

ចរណៈ ប្រែថា “ការប្រព្រឹត្ត, ការត្រាច់ទៅ ឬការដើរ” ។ ចរណៈនេះជាឈ្មោះបដិបទារបស់ព្រះពុទ្ធជាម្ចាស់ ឬ ពុទ្ធសាវ័ក ដែលព្រះអង្គមានចរណៈដ៏បរិបូណ៌ សំដៅយកការប្រព្រឹត្តល្អដោយកាយ វាចា ចិត្តឥតមានបុគ្គលណាមួយ ចាប់ផ្ទាក់ ចោទប្រកាន់ក្នុងផ្លូវសីលធម៌ ឬ រង្កៀសចំពោះសេចក្តីប្រព្រឹត្តិព្រះអង្គបានឡើយ។ ចរណៈទាំង១៥ចែកចេញជា៣ពួកគឺ សីល ជាពួកទី១ សទ្ធម្ម ជាពួកទី២ ឈាន ជាពួកទី៣។

ពួកទី១ សីល
១-សីលសំវរៈ សង្រួមកាយវាចាតាមសិក្ខាបទនៃសីល។
២-ឥន្ទ្រិយសំវរៈ សង្រួមឥន្ទ្រិយទាំង ៦ បានដល់ ១-ចក្ខុន្ទ្រីយ គឺភ្នែក, ២-សោតិន្ទ្រិយ គឺត្រចៀក, ៣-ឃានិន្ទ្រិយ គឺច្រមុះ, ៤-ជីវ្ហិន្ទ្រិយ គឺអណ្តាត, ៥-កាយិន្ទ្រិយ គឺកាយ និង ៦-មនិន្ទ្រិយ គឺចិត្ត។
៣-ភោជនេ មត្តញ្ញុតា សេចក្តីដឹងប្រមាណក្នុងភោជន។
៤-ជាគរិយានុយោគៈ ប្រកបរឿយៗក្នុងការភ្ញាក់រលឹក។

ពួកទី២ សទ្ធម្ម ៧យ៉ាង
៥-សទ្ធា ការជឿហេតុផលដែលគួរជឿ។
៦-ហិរិ សេចក្តីខ្មាស់បាប។
៧-ឱតប្បៈ សេចក្តីតក់ស្លុតខ្លាចបាប។
៨-ពាហុសច្ចៈ ភាពជាអ្នករៀនសូត្រច្រើន។
៩-វីរយៈ សេចក្តីប្រឹងប្រែង។
១០-សតិ សេចក្តីរលឹកចាំបាន។
១១-បញ្ញា ការដឹងច្បាស់ទូទៅ។

ពួកទី៣ រូបជ្ឈាន
ពាក្យថា “ឈាន” ប្រែថា “ការដុតកំដៅនូវនីវរណៈ, ការពិនិត្យសម្លឹងនូវអារម្មណ៍” ដើម្បីបង្វឹកចិត្តទាល់តែកើត អប្បនាសមាធិជាលំដាប់ តាំងពីឈានថ្នាក់ទាបរហូតដល់ថ្នាក់ខ្ពស់។

១២-បឋមជ្ឈាន ឈានទី ១ ប្រកបដោយអង្គ៥ គឺ ១-វិតក្កៈ សេចក្ដីនឹកសំដៅឆ្ពោះទៅរកអារម្មណ៍ដែលកំពុង ភាវនា។ ២-វិចារៈ សេចក្ដីរំពឹងពិចារណាអារម្មណ៍ដែលកំពុងភាវនា។ ៣-បីតិ សេចក្ដីឆ្អែតចិត្ត ។ ៤-សុខៈ សេចក្ដីសប្បាយក្នុងចិត្ត។ ៥-ឯកគ្គតា ដំណើរមូលចិត្តស្លុងទៅ ក្នុងអារម្មណ៍តែមួយ។

១៣-ទុតិយជ្ឈាន ឈានទី២ ប្រកបដោយអង្គ៣ គឺ បីតិ សុខៈ ឯកគ្គតា។ លះនូវវិតក្កៈ និង វិចារៈ។
១៤-តតិយជ្ឈាន ឈានទី ៣ ប្រកបដោយអង្គ២ គឺសុខៈ ឯកគ្គតា។ លះវិតក្កៈ វិចារៈ និង បីតិ ។
១៥-ចតុត្ថជ្ឈាន ឈានទី៤ ប្រកបដោយអង្គ២ គឺ ឯកគ្គតា និង ឧបេក្ខា។ លះវិតក្កៈ វិចារៈ បីតិ និង សុខៈ។

ឈានទាំងបួនថ្នាក់នេះ ហៅថា រូបជ្ឈាន ជាឈានមានរូបធម៌ជាអារម្មណ៍រាប់បញ្ចូលក្នុងរូបាវចរភូមិ ។ បុគ្គលអ្នកចម្រើនភាវនា បានសម្រេចផ្លូវឈាន សូម្បីត្រឹមតែ បឋមជ្ឈានប៉ុណ្ណោះ ក៏ជួបប្រទះសេចក្ដីសុខសប្បាយធម្មតា ឆ្ងាញ់ពិសាជាងរសជាតិអ្វីៗទាំង អស់។
ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់បរិបូណ៌ដោយចរណៈទាំង១៥នេះឥតមានខ្វះចន្លោះត្រង់ណាឡើយ។

សិក្សាពាក្យ
រូបជ្ឈាន (រូប៉ុច-ឈាន) ឈានដែលមានរូបធម៌ជាអារម្មណ៍ ។
អប្បនាសមាធិ (អ័ប-ប៉ៈ ន៉ា–) សមាធិដែលចុះស្លុងស៊ប់ក្នុងអង្គឈានពេញបរិបូរ ។
រូបភព (រូប៉ៈភប់) កន្លែងកើតនៃរូបព្រហ្ម។
រូបាវចរ (រូប៉ាវ៉ៈចៈរៈ ឬ-ច; បា. <រូប + អវចរ) ចិត្តដែលត្រាច់រង្គាត់ ឬអន្ទោលទៅ ក្នុងរូបភព ។
រូបាវចរភូមិ (រូប៉ាវៈចៈរៈ ភូម; បា. <រូប + អវចរ + ភូមិ) ភូមិ, ទី ឬថ្នាក់របស់រូបាវចរ ។
ឥន្ទ្រិយ ឬ ឥន្ទ្រីយ៍ (អិន-ទ្រី)ភាវៈជាធំ, ឥស្សរភាព; អានុភាព, អំណាច; គុណានុភាពឬគុណសម្បត្តិរបស់ព្រះឥន្ទ្រឬដែលជាប់ទាក់ទងអំពីព្រះ ឥន្ទ្រកម; រូបកាយ; កម្លាំង, កម្លាំងកាយ; សេចក្ដីដឹង, ប្រាជ្ញា; អារម្មណ៍; មុខការ, នាទី; អាយតនៈខាងក្នុង, ប្រសាទឬប្រសាទរូប : សង្រួម ឥន្ទ្រិយ ប្រុងប្រយ័ត្នអាយតនៈខាងក្នុងមានភ្នែកជាដើម។ ឥន្ទ្រិយ សព្ទនេះមានន័យច្រើនយ៉ាងណាស់, ព. ពុ. ប្រាប់ថាអ្វីដែលជាធំ តាមមុខតាមនាទីរបស់ខ្លួនឬដែលមានបែបភាពផ្សេងដោយឡែកហៅថា ឥន្ទ្រិយ, ដូចជា ភ្នែក ហៅ ចក្ខុន្ទ្រិយ; ត្រចៀក ហៅ សោតិន្ទ្រិយ; ច្រមុះ ហៅ ឃានិន្ទ្រិយ; អណ្ដាត ហៅ ជីវ្ហិន្ទ្រិយ; កាយ ហៅ កាយិន្ទ្រិយ; មនោ ឬ ចិត្ត ហៅ មនិន្ទ្រិយ (ព្រោះអាយតនៈខាងក្នុងទាំង

៦ នេះជាធំក្នុងការទទួល អារម្មណ៍តាមនាទីរបស់ខ្លួន ជាជំនួសគ្នាពុំបាន) ។
(វចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត)
សិក្ខាបទ (–បត់) ចំណែក, មាត្រារបស់សីលឬរបស់វិន័យ ។
នីវរណៈ = ធម៌ដែលជាគ្រឿងរាំងចិត្តមិនឲ្យបានសម្រេចសេចក្ដីល្អ ហៅថា នីវរណធម៌
មាន ៥យ៉ាងគឺ:
១- កាមច្ឆន្ទៈស្រឡាញ់ចូលចិត្តក្នុងអារម្មណ៍មានរូបជាដើម ដែលជាទីគាប់ចិត្ត។
២- ព្យាបាទៈ ចងចិត្តគំនុំគុំគួនអ្នកដទៃ។
៣- ថីនមិទ្ធៈ ដំណើរដែលចិត្តរួញថយ និងដំណើរងុយងោកងក់។
៤- ឧទ្ធច្ចកុក្កុច្ចៈ (អ៊ុត-ធាច់ចៈ – កុកកុច ចៈ) ដំណើរដែលចិត្តរាយមាយនិងរសាប់រសល់។
៥- វិចិកិច្ឆា សេចក្ដីសង្ស័យមិនចេះដាច់ស្រេច។

សូមអស់លោកអ្នកអនុមោទនា !

ចប់